ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៛៚

តុលាការកំពូល

៚

សភាជំនុំក្រុមព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២២

ចុះថ្ងៃទី២៤ខែមេសាឆ្នាំ១៩៩៨

សាលដីកា

លេខ : ០៣

ចុះថ្ងៃទី១៧ខែកុម្ភៈឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៩ ដោយ មានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក សោម សិរីវឌ្ឍ ចៅក្រម

៤- លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍

៥- លោក យស់ សូខឿន ចៅក្រម

លោក កេង ចាន់ថា ក្រឡាបញ្ជី

តំណាងមហាអយ្យការ លោក ជួន ស៊ុនឡេង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ២២ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ១៩៩៨ របស់តុលាការកំពូល :

ពីបទ : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិ សាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥ ខែ មិនា ឆ្នាំ១៩៩៣ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១- ជនជាប់ចោទឈ្មោះ អ៊ឹង ម៉ុយអេង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៣១ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅបច្ចុប្បន្ន ភូមិសាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ឪពុកឈ្មោះ ម៉ាក់ គីម "ប" ម្តាយឈ្មោះ ជាម សុគាង "រ" ប្តីឈ្មោះ នួន គីមហេង មានកូន២នាក់ ទោសពីមុន គ្មាន មេធាវី លោក ជុំ សុវណ្ណាលី "នៅក្រៅឃុំ" អវត្តមាន ។

២- ជនជាប់ចោទឈ្មោះ អ៊ឹង មុយឡេង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ២៨ ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅបច្ចុប្បន្ន ភូមិសាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ឪពុកឈ្មោះ ម៉ាក់ គីម "ល" ម្តាយឈ្មោះ ជាម សុគាង "រ" ប្តីឈ្មោះ យ ទ្រី មានកូន ២ នាក់ ទោសពីមុនគ្មាន មេធាវីលោក ជុំ សុវណ្ណាលី "នៅក្រៅឃុំ" អវត្តមាន ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ញ៉ាក់ សុង "ចុងបណ្តឹងសាទុក្ខ" ភេទប្រុសអាយុ៣០ឆ្នាំជាតិខ្មែរ

នៅភូមិសាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ របរកសិកម្មធ្វើស្រែ ។ ឪពុកឈ្មោះ គីម ឡេងវី ម្តាយឈ្មោះ ទិន ទៀង ប្រពន្ធឈ្មោះ គីម វ៉ង មានកូន ២ នាក់ មេធាវីគ្មាន "អវត្តមាន"

តាមបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ១៩៩៨ របស់ឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

តាមពាក្យបណ្តឹងរបស់ឈ្មោះ ញ៉ុក សុង ប្តឹងពីឈ្មោះ អ៊ឹង មុយអេង ដែលបានប្រើសិទ្ធិរំលោភវាយប្រពន្ធខ្លួន បណ្តាលអោយសន្លប់បាត់ស្មារតី ។ ខ្លួនទាមទារជំងឺចិត្ត និង សោហ៊ុយចំនួន ២០ តំឡឹងមាស ។

- បានឃើញរបាយការណ៍លេខ ២៨៧/៩៣ របក ចុះថ្ងៃទី ១០/៥/៩៣ របស់អធិការនគរបាលស្រុកស្ទោង បានរាយការណ៍ថា : កាលពីថ្ងៃទី ២៥/៣/៩៣ វេលាម៉ោង ៦ ល្ងាច នារីពីរនាក់ ឈ្មោះ មុយអេង និង មុយឡេង រួមគ្នាធ្វើសកម្មភាពវាយនឹងដំបងទៅលើនារីឈ្មោះ គីម វ៉ង ដែលកំពុងធ្វើដំណើរដោយកង់ ព្រមទាំងឱបកូនតូចពីក្រោយផង បណ្តាលអោយនារី គីម វ៉ង មានរបួសស្នាមយ៉ាងធ្ងន់ធ្ងរនៅលើក្បាល ។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ២៧ អក/៩៣ ចុះថ្ងៃទី ១៨/៥/៩៣ របស់អយ្យការអមតុលាការខេត្តកំពង់ធំ ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរ លេខ ៩១ អក/៩៤ ចុះថ្ងៃទី ២៣/៤/៩៤ របស់អយ្យការអមតុលាការខេត្តកំពង់ធំ ដែលបានសំរេចចោទប្រកាន់ឈ្មោះ អ៊ឹង មុយអេង ភេទស្រី អាយុ ៣០ ឆ្នាំ និង ឈ្មោះ អ៊ឹង មុយឡេង ភេទស្រី អាយុ ២៨ ឆ្នាំ ពីបទបង្ករបួសស្នាមដោយចេតនា មានបក្សពួក មានអាវុធ ប្រព្រឹត្តនៅភូមិសាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥/៣/៩៣ បទល្មើសព្រហ្មទណ្ឌ ដោយមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៤៨ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៤ របស់តុលាការខេត្តកំពង់ធំ ដែលបានសំរេចសេចក្តីដូចតទៅ :

១- ផ្តន្ទាទោសឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ដាក់ពន្ធនាគារកំណត់រយៈពេល ១ ឆ្នាំ ក្នុងម្នាក់ៗ គិតពីថ្ងៃចាប់ខ្លួន ពីបទបង្ករបួសស្នាមដោយចេតនា មានបក្សពួក មានអាវុធ ប្រព្រឹត្តនៅភូមិសាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥/៣/៩៣ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- អោយឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង រួមរ៉ូតគ្នាសងថ្លៃការព្យាបាល និង ជំងឺចិត្ត ចំនួន ៣ តំឡឹងមាសទឹកដប់ ទៅអោយឈ្មោះ ញ៉ុក សុង ជាដើមបណ្តឹងរដ្ឋប្បវេណី ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះ កំបាំងមុខជនល្មើស បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងទាស់ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ១៩៩៤ របស់ឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ដែលប្តឹងមិនសុខចិត្តពីសាលក្រមលេខ ៤៨ ចុះថ្ងៃទី២១/៩/៩៤ របស់តុលាការខេត្តកំពង់ធំទាំងមូល

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៨ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ១៩៩៤ របស់តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងទាស់ចុះថ្ងៃទី ១៣.៦.៩៤ របស់ជនជាប់ចោទឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៨ ចុះថ្ងៃទី ២១.៦.៩៤ ទុកជាបានការពេញទាំងមូល ។

៣ - សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទកំបាំងមុខជនរងគ្រោះ របីភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៤ របស់ឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ប្តឹងមិនសុខចិត្តពីសាលក្រមលេខ ៥៨ ចុះថ្ងៃទី២៣.១១.៩៤របស់តុលាការខេត្តកំពង់ធំទាំងមូល ។ - បានឃើញតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍សន្និដ្ឋានថា : បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ត្រឹមត្រូវតាមទំរង់ច្បាប់ ហើយសុំតម្កល់សាលក្រមតុលាការខេត្តកំពង់ធំលេខ ៥៨ ចុះថ្ងៃទី ២៣.១១.៩៤ ទុកជាបានការ ប៉ុន្តែត្រូវបញ្ជាក់អំពីការអនុវត្តបញ្ញត្តិច្បាប់ មាត្រា ៤១ អោយបានត្រឹមត្រូវនិង កែប្រែសំណងជំងឺចិត្តដោយប្រើប្រាស់ប្រាក់រៀល ។

- បានឃើញសាលដីកា ព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣.៦.៩៤ របស់ជនជាប់ចោទឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែអំពីគតិច្បាប់ លើកចោលខ្លះ ទុកខ្លះ ។

២ - តម្កល់សាលក្រមលេខ ៥៨ ចុះថ្ងៃទី ២៣.១១.៩៤ របស់តុលាការខេត្តកំពង់ធំទាំងមូលទុកជាបានការ តែអំពីការផ្តន្ទាទោស ត្រូវព្យួរ ដោយសាកល្បងរយៈពេល ៥ ឆ្នាំ តាមមាត្រា ៤១,៦៨ ,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ តែចំណុចទី ១ និង ទី២ ត្រូវកែប្រែដូចតទៅ :

ផ្តន្ទាទោសឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន៦ឆ្នាំ តែទោសនេះ ត្រូវព្យួរ ដោយដាក់អោយសាកល្បងកំណត់ ៥ ឆ្នាំ គិតពីថ្ងៃកាត់សេចក្តី ពីបទបង្កប្លន់ឃាតដោយចេតនា មានបក្សពួក មាន អាវុធ ប្រព្រឹត្តនៅឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥.៣.៩៣ តាមបញ្ញត្តិមាត្រា ៤១,៦៨,៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ឯជំងឺចិត្ត បន្ថយពី ៣ តំឡឹងមាស មកនៅត្រឹម ២ លាន ៥ សែនរៀល " ២.៥០០.០០០រៀល " ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនល្មើស និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ១៩៩៨របស់ឈ្មោះអ៊ឹងមុយអេង និង អ៊ឹង មុយឡេង ប្តឹងមិនសុខចិត្តលើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាការពារចុះថ្ងៃទី២០.៧.៩៨ របស់ឈ្មោះអ៊ឹង មុយអេង និងអ៊ឹង មុយឡេង ផ្ញើទៀងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី ៣០.១០.៩៨ របស់ឈ្មោះ ញ៉ុក សុង ផ្ញើទៀងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា : ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងមូលមក យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៥-១១-១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែអង្គច្បាប់ ខុសខ្លះ ត្រូវខ្លះ ។ ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

- បានស្តាប់សារណារបស់ឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង

- បានស្តាប់សារណាតបរបស់ឈ្មោះ ញ៉ុក សុង

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ថា : ការដែលកូនក្តីរបស់ខ្លួនប្តឹងនេះ គឺមិនប្តឹងសាទុក្ខទាំងមូលទេ គឺប៉ុន្តែសុំអោយក្រុមប្រឹក្សាជំនុំជំរះមេត្តាបន្ធូរបន្ថយអោយបានទាបផង ព្រោះសព្វថ្ងៃនេះ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រលំបាកណាស់ ហើយម្យ៉ាងទៀត បើប្រៀបធៀបបទល្មើសលើកទី ១ និង បទល្មើសលើកទី ២ នេះ ឃើញថា កូនក្តីរបស់ខ្លួនត្រូវសងទៅដើមបណ្តឹងរដ្ឋប្បវេណីមានកំរិតខ្ពស់ ហេតុនេះមកខ្លួនដែលជាមេធាវីការពារអោយជនជាប់ចោទ សុំអោយក្រុមប្រឹក្សាជំនុំជំរះមេត្តាបន្ធូរបន្ថយអោយបានទាប ដែលកូនក្តីរបស់ខ្លួនត្រូវសងទៅដើមបណ្តឹងនេះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ សារណារបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទឈ្មោះ អ៊ឹង មុយអេង និង អ៊ឹង មុយឡេង ក្នុងសារណាចុះថ្ងៃទី ២០-៣-១៩៩៨ ថា បើប្រៀបធៀបរវាងរឿងក្តីរបស់ខ្លួន និង មាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលតុលាការធ្វើការចោទប្រកាន់មកលើភាគីខាងខ្លួន គឺវាមិនសមស្របពីព្រោះថា រឿងក្តីនេះ ភាគីម្ខាងទៀតមានការវាយតបមកលើខ្លួនដែរ ចុះហេតុអ្វីបានជាតុលាការមិនចោទប្រកាន់កំហុសលើភាគីម្ខាងទៀតនោះផង នោះគឺជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថា :

. មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា នៅថ្ងៃកើតហេតុ ជនជាប់ចោទទាំងពីរនាក់ គឺឈ្មោះ អ៊ឹង មុយអេង និង ឈ្មោះ អ៊ឹង មុយឡេង បានត្រៀមដំបងជាស្រេចឈរចាំស្ទាក់វាយជនរងគ្រោះ ហើយពេលជនរងគ្រោះជិះកង់មកដល់ ក៏វាយជនរងគ្រោះអោយដួលដេកលើថ្នល់ ហើយអូសជនរងគ្រោះចូលទៅក្នុងរបងផ្ទះអ្នកជិតខាង ហើយវាយបន្ថែមទៀត បណ្តាលអោយជនរងគ្រោះមានរបួសច្រើនកន្លែង ពិសេសរបួសនៅក្បាល ។

. ជនរងគ្រោះម្នាក់ឯងដែលទទេ ជិះកង់ចុះកូនតូចពីក្រោយ ពុំអាចវាយបកទៅលើជនជាប់ចោទបានឡើយ ។

- យល់ឃើញថា ក្នុងសេចក្តីសំរេចចំណុចទី ១ សាលាឧទ្ធរណ៍មានការខុសឆ្គងអំពីកាលបរិច្ឆេទនៃបណ្តឹងឧទ្ធរណ៍ដោយដាក់ថា បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-៩-៨៤ តាមពិតបណ្តឹងឧទ្ធរណ៍មានកាលបរិច្ឆេទថ្ងៃទី ២៩-១២-៨៤ ប៉ុន្តែដោយកំហុសនេះជាកំហុសផ្នែកសំភារៈ តុលាការកំពូលអាចកែតំរូវបាន ។

- យល់ឃើញថា ក្នុងការយល់ឃើញ ក៏ដូចក្នុងសេចក្តីសំរេចចំណុចទី ១ តុលាការខេត្តកំពង់ធំ មានការខុសឆ្គងអំពីកាលបរិច្ឆេទនៃបណ្តឹងទាស់ ដោយដាក់ថា បណ្តឹងទាស់ចុះថ្ងៃទី ១៣-៩-៨៤ តាមពិតបណ្តឹងទាស់មានកាលបរិច្ឆេទថ្ងៃទី ១៣-១០-៨៤ ប៉ុន្តែដោយកំហុសនេះជាកំហុសផ្នែកសំភារៈ តុលាការកំពូលអាចកែតម្រូវបាន ។

- យល់ឃើញថា សាលាឧទ្ធរណ៍មានការភ័ន្តច្រឡំក្នុងការសំរេចសេចក្តី ត្រង់ចំណុចទី២ អំពីការអនុវត្តទណ្ឌកម្ម ដោយគិតពីថ្ងៃកាត់សេចក្តី ប៉ុន្តែដោយជនជាប់ចោទជាម្ចាស់បណ្តឹងសាទុក្ខ តុលាការកំពូលពុំអាចបន្ថែមទំងន់ទោសទៅលើជនជាប់ចោទបានទេឡើយ ។

- យល់ឃើញថា ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៨៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែអំពីគតិច្បាប់ខុសខ្លះ ត្រូវខ្លះ ។

**ហេតុ ដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវីជនជាប់ចោទ**

**កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី២៣ខែមករាឆ្នាំ១៩៨៨ របស់ជនជាប់ចោទឈ្មោះ អ៊ឹង មុយអេង និង ឈ្មោះ អ៊ឹង មុយឡេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៣៤ ចុះថ្ងៃទី ២៨-១១-៨៧ របស់សាលាឧទ្ធរណ៍ទុកជាបាន ការលើកលែង - ចំណុចទី១ នៃសេចក្តីសំរេចត្រង់កាលបរិច្ឆេទនៃបណ្តឹងឧទ្ធរណ៍ ត្រូវកែតំរូវមកជាបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣-៩-៨៤ វិញ ។

- ក្នុងការយល់ឃើញ និង សេចក្តីសំរេចចំណុចទី១ នៃសាលក្រមលេខ ៥៨ ចុះថ្ងៃទី២៨-១១-៨៤ របស់តុលាការខេត្តកំពង់ធំ ត្រង់កាលបរិច្ឆេទនៃបណ្តឹងទាស់ ត្រូវកែតម្រូវមកជាបណ្តឹងទាស់ចុះថ្ងៃទី ១៣-១០-៨៤ វិញ ។

៣- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ១៩៨៨ ។